# ស្តីពីលក្ខណៈសម្បត្តិស្នាក់នៅ(zairyushikaku)របស់និស្សិតបរទេស

*នេះជាពត៌មាននៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

● អ្នកដែលត្រូវបន្តការសិក្សានៅសាលា

**◆ អាចពន្យាលក្ខណៈសម្បត្តិស្នាក់នៅជា "ការសិក្សានៅបរទេស (ryugaku)" បាន**

-ទោះបីជាផ្លាស់ប្តូរសាលា ក៏អាចពន្យាបានដែរ
-ប្រសិនបើទទួលបានការអនុញ្ញាតលើ "សកម្មភាពក្រៅពីលក្ខណៈសម្បត្តិ(shikakugaikatsudo)"នោះអាចធ្វើការងារក្រៅម៉ោងបានដល់ ២៨ ម៉ោងក្នុង ១សប្តាហ៍
-អ្នកដែលសិក្សានៅសាលាភាសាជប៉ុន អាចបន្តការសិក្សាបាន ទោះជាផុតរយៈពេល ២ឆ្នាំក៏ដោយ (ករណីនេះសូមធ្វើការពន្យាលក្ខណៈសម្បត្តិស្នាក់នៅជា "ការសិក្សានៅបរទេស")

● អ្នកដែលបានបញ្ចប់ការសិក្សា តែមិនអាចត្រឡប់ទៅប្រទេសវិញ

**◆ អាចប្តូរលក្ខណៈសម្បត្តិស្នាក់នៅទៅជា "សកម្មភាពកំណត់ជាក់លាក់(tokuteikatsudo)(រយៈពេល ៦ខែ)"**

-អ្នកចង់ធ្វើការ អាចធ្វើការក្រៅម៉ោងបាន ២៨ម៉ោងក្នុង ១សប្តាហ៍ (មិនចាំបាច់មានការអនុញ្ញាតលើ "សកម្មភាពក្រៅពីលក្ខណៈសម្បត្តិ" ទេ)
-អ្នកដែលបានប្តូរលក្ខណៈសម្បត្តិស្នាក់នៅពី "ការសិក្សានៅបរទេស" ទៅជា "ការស្នាក់នៅរយៈពេលខ្លី(tankitaizai)" ឬ "សកម្មភាពកំណត់ជាក់លាក់(រយៈពេល ៦ខែ・មិនអាចធ្វើការងារបាន)" ហើយក៏ដោយ ក៏អាចផ្លាស់ប្តូរបានទៀតដែរ
-គ្រួសារនិស្សិតបរទេស ឬគ្រួសារអតីតនិស្សិតបរទេស ក៏អាចប្តូរលក្ខណៈសម្បត្តិស្នាក់នៅ បានដែរ

**◆ អ្នកដែលនៅមានលក្ខណៈសម្បត្តិស្នាក់នៅជា "ការសិក្សានៅបរទេស" ហើយទទួលបានការអនុញ្ញាតលើ "សកម្មភាពក្រៅពីលក្ខណៈសម្បត្តិ" ទោះជាបានបញ្ចប់ការសិក្សាក៏ដោយ ក៏អាចធ្វើការងារក្រៅម៉ោងបាន ២៨ម៉ោងក្នុង១សប្តាហ៍ដែរ**

新型コロナウイルス感染下における
外国にルーツがある人々への支援活動応援助成
三菱財団 × 中央共同募金会
原稿作成・翻訳：NPO法人 多言語センターFACIL
https://tcc117.jp/facil/
FACIL

● អ្នកដែលទទួលបានការងារនៅប្រទេសជប៉ុនក្រោយបញ្ចប់ការសិក្សា
◆ ប្រសិនបើបំពេញលក្ខខណ្ឌ អាចប្តូរលក្ខណៈសម្បត្តិស្នាក់នៅទៅជា “វិស្វកម្ម · មនុស្សសាស្ត្រ · សេវាកម្មអន្តរជាតិ(gijyutsu jinbunchishiki kokusaigyomu)” បាន

● អ្នកដែលចង់ស្វែងរកការងារនៅប្រទេសជប៉ុនក្រោយបញ្ចប់ការសិក្សា
(*សម្រាប់អ្នកដែលបញ្ចប់កម្រិតសាកលវិទ្យាល័យ សាលាជំនាញជាន់ខ្ពស់ សាលាជំនាញ ប៉ុណ្ណោះ)
◆ ប្តូរលក្ខណៈសម្បត្តិស្នាក់នៅទៅជា “សកម្មភាពកំណត់ជាក់លាក់” ហើយអាចធ្វើសកម្មភាពស្វែងរកការងារបានរយៈពេល ១ឆ្នាំ ក្រោយបញ្ចប់ការសិក្សា
-ប្រសិនបើធ្វើការពន្យារទៀត អាចបន្តសកម្មភាពស្វែងរកការងារនៅជប៉ុនបាន ទោះជាផុតរយៈពេល១ឆ្នាំក៏ដោយ
-ប្រសិនបើទទួលបានការអនុញ្ញាតលើ “សកម្មភាពក្រៅពីលក្ខណៈសម្បត្តិ” នោះអាចធ្វើការងារក្រៅម៉ោងបាន ២៨ ម៉ោងក្នុង ១សប្តាហ៍

ស្ថាប័នដែលអាចពិភាក្សាអំពី លក្ខណៈសម្បត្តិស្នាក់នៅ បានជាច្រើនភាសា
សមាគមវប្បធម៌តំបន់ (chiikikokusaikakyokai)
http://www.clair.or.jp/j/multiculture/association/consultation_list.html
សេវាទូរស័ព្ទយ៉ូរីសូយ (yorisoi hotline)
https://www.since2011.net/yorisoi/

新型コロナウイルス感染下における
外国にルーツがある人々への支援活動応援助成
三菱財団 × 中央共同募金会
原稿作成・翻訳：NPO法人 多言語センターFACIL
https://tcc117.jp/facil/
FACIL

ឯកសារយោង

“ការកំណត់ទាក់ទងជនបរទេសដែលមានផលវិបាកក្នុងការត្រលប់ទៅប្រទេសកំណើត”
(ការិយាល័យគ្រប់គ្រងការស្នាក់នៅនិងការចេញចូលប្រទេស កែសម្រួលថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២០)
http://www.moj.go.jp/isa/content/930005847.pdf
→ភាសាផ្សេងៗ សូមចុចទីនេះ
http://www.moj.go.jp/isa/nyuukokukanri01_00155.html

“ស្តីពីការកំណត់ទាក់ទងនឹងការដាក់ពាក្យស្នើសុំការស្នាក់នៅពីអ្នកស្នាក់នៅរយៈពេលវែង និងមធ្យម និងអតីតអ្នកស្នាក់នៅរយៈពេលវែង និងមធ្យមដែលមានផលវិបាកក្នុងការត្រលប់ទៅប្រទេសវិញដោយសារឥទ្ធិពលនៃជម្ងឺកូវីដ”
(ការិយាល័យគ្រប់គ្រងការស្នាក់នៅនិងការចេញចូលប្រទេស កែសម្រួលថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២០)
http://www.moj.go.jp/content/001320105.pdf

“ស្តីពីដំណោះស្រាយសម្រាប់និស្សិតបរទេសដែលទទួលរងឥទ្ធិលពលនៃការរីករាលដាលជម្ងៃកូវីដ”
(ការិយាល័យគ្រប់គ្រងការស្នាក់នៅនិងការចេញចូលប្រទេស កែសម្រួលថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២០)
http://www.moj.go.jp/content/001318472.pdf

新型コロナウイルス感染下における
外国にルーツがある人々への支援活動応援助成
三菱財団 × 中央共同募金会
原稿作成・翻訳：NPO法人 多言語センターFACIL
https://tcc117.jp/facil/
FACIL